# ចំណាប់អារម្មណ៍របស់ខ្ញុំ
## ដោយ ស៊ឹង លីហេង
## ភ្នំពេញ

បន្ទាប់ពីបានស្តាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា វគ្គទី៨ ដែលប្រធានបទនៃវគ្គនេះស្តីអំពី សំណុំរឿងពាក់ពន្ធ័នឹង លោក ហ្វ្រែង (The Frank Case) និងពត៌មានថ្មីៗទាក់ទងនឹងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម អំពីការបែងចែកស្រូវនៅសម័យខ្មែរក្រហមហើយ។ ខ្ញុំយល់ឃើញថា រវាងសំណុំរឿងពាក់ពន្ធ័នឹង លោក ហ្វ្រែង ដែលបានកើតឡើងក្នុងអំឡុង សម័យសង្គ្រាមលោកលើកទីពីរនៅឯប្រទេសប៉ូឡូញ និង ករណីខ្មែរក្រហម មានលក្ខណៈស្រដៀងគ្នាខ្លះ និងមានចំណុចខុសគ្នាផ្សេងៗដែលគួរឲ្យកត់សំគាល់ ប៉ុន្តែបើមើលក្នុងបរិបថទូទៅ គឺមានចរិកនៃបទឧក្រិដ្ឋ ឬចរិកនៃបទល្មើស គឺដូចគ្នាតែមួយ។

ជាដំបូងខ្ញុំចាប់អារម្មណ៍ទៅលើលក្ខណៈស្រដៀងគ្នារវាងសំណុំរឿងរបស់ លោក ហ្វ្រែង និងករណីខ្មែរក្រហម គឺថាការប្រើប្រាស់កំម្លាំពលកម្មរបស់ប្រជាជនស៊ីវិល ដើម្បីបម្រើដល់គោលដៅ និងគោលបំណងរបស់ពួកគេ ខណៈពេលដែលប្រជាជនស៊ីវិលស្ថិតនៅក្រោមការ គ្រប់គ្រង និងត្រួតត្រារបស់ពួកគេ។ ករណីទាំងពីរនេះមានស្ថានភាពដូចគ្នាគឺការប្រើប្រាស់កម្លាំរបស់ប្រជាជន ដើម្បីផលិតស្បៀងអាហារក្នុងស្ថានភាពបង្ខំ និងសិទ្ធិចំបងមួយ ចំនួនត្រូវបានដកហូត សូម្បីតែការទទួលបានចំនីអាហារជាដើម។ មិនត្រឹមតែប៉ុណ្ណោះ ផលប៉ះពាល់ចំពោះការប្រើប្រាស់កម្លាំរបស់ប្រជាជនដែលហួសកំរិតនៅ ក្នុងករណីទាំងពីរនេះ គឺមានផលប៉ះពាល់ប្រហាក់ប្រហែលគ្នា ដែលធ្វើឲ្យប្រជាជនស៊ីវិលទទួលបាននូវលក្ខខណ្ឌរស់នៅដ៏លំបាកវេទនា រួមមាន គ្រោះអត់ឃ្លាន ជម្ងឺ និងការអត់អាហារ ដែលឈានទៅដល់ការស្លាប់ជាទ្រង់ទ្រាយធំ ខណៈពេលស្បៀងដែលផលិតបានលើសពីតម្រូវការរបស់ ទ័ពអាល្លឺម៉ង់ ឬ តម្រូវការរបស់បក្សកម្មុយនីស្តកម្ពុជាសម្រាបើនាំចេញក៏ដោយ។ ចំនែកឯភាពខុសគ្នារវាង សំណុំរឿង លោក ហ្វ្រែង និងករណីខ្មែរក្រហម គឺសកម្មភាពដែលបានប្រព្រឹត្តដោយអាល្លឺម៉ង់ចំពោះប្រជាជនប៉ូឡូញ ក្នុងការប្រប្រាស់កម្លាំពលកម្មរបស់ប្រជាជនជាច្រើនរបស់ប៉ូឡូញ ដែលជាជាតិសាសន៍ដទៃ ដើម្បីផលិតស្បៀងបំរើ សមរភូមិទ័ពរបស់ខ្លួន ពេលដែលខ្លួនកាន់កាប់ប្រទេសប៉ូឡូញ តែផ្ទុយទៅវិញក្នុងករណី ខ្មែរក្រហម ពួកគេបែរជា យកប្រជាជនខ្លួនឯង ដែលជាជាតិសាសន៍ខ្មែរតែមួយទូទាំងប្រទេសទៅធ្វើជាទាសករ ប្រើប្រាស់កម្លាំងពលកម្មយ៉ាងធ្ងន់ធ្ងរ ទៅផលិតស្បៀងដើម្បីបម្រើបដិវត្តន៍របស់ខ្លួន។ រីឯភាពផ្ទុយគ្នាមួយទៀត រវាងករណី លោក ហ្វ្រែង និងករណីខ្មែរក្រហម គឺគោលដៅនៃប្រើប្រាស់កម្លាំងពលកម្ម របស់អាល្លឺម៉ង់ទៅលើប្រជាជនប៉ូឡូញ គឺដើម្បីបំពេញតម្រូវការរបស់យោធាអាល្លឺម៉ង់សម្រាប់ការសង្គ្រាម ទើបនាំឲ្យប្រជាជនប៉ូឡូញខ្វះរបបអាហារយ៉ាងធ្ងន់ធ្ងរបែបនេះ តែបើយើងក្រលែកមើលទៅករណី

របស់ខ្មែរក្រហមវិញ ពួកគេប្រើប្រាស់កម្លាំងពលកម្មរបស់ប្រជាជនកម្ពុជាទូទាំងប្រទេស ដើម្បីនាំចេញទៅបរទេសយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅវិញ ក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្លួន ទោះបីជាប្រជាជនខ្លួនប្រជាជនខ្លួនរាប់ពាន់អ្នកត្រូវស្លាប់ដោយសារការខ្វះរបបអាហារក៏ដោយ នេះបើយោងតាមការផ្តល់សក្ខីកម្មរបស់សាក្សី វាគឺផ្ទុយស្រលះពីអាល្លឺម៉ង់ ខ្មែរក្រហមបែរជាកយកស្បៀងដែលផលិតដោយការប្រើកម្លាំពលកម្មរបស់ប្រជាជនខ្មែរទៅផ្គត់ផ្គង់ឲ្យបរទេស ឬចិនទៅវិញយោងតាមសំដីសារបស់ក្សី និងអតីតកម្មករធ្វើការនៅកំពង់ផែកំពង់សោមនាសម័យនោះ។

ទោះបីជាសំណុំរឿង លោក ប្រ៉ែង និងករណីខ្មែរក្រហមមានលក្ខណៈ និងចំណុចខុសគ្នាច្រើន ឬតិចយ៉ាងណាក្តី បើយើងមើលក្នុងបរិបថទូទៅវិញ អំពើដែលបានកើតឡើងនៅក្នុងសំណុំរឿង លោក ប្រ៉ែង និងករណីខ្មែរក្រហម គឺជាសកម្មភាពពីរ ដែលមានចរិកនៃអំពើដូចគ្នា ដែលបានប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំយ៉ាងធ្ងន់ធ្ងរ និងបង្កឲ្យមានការអត់ឃ្លាន ថែមទាំមានលក្ខខណ្ឌរស់នៅយ៉ាងលំបាកដូចគ្នា ដូចនេះខ្ញុំអាចនិយាយបានថាសកម្មភាពទាំង ពីរស្តែងចេញនូវផលប៉ះពាល់ដល់មនុស្សជាតិយ៉ាងធ្ងន់ធ្ងរ ហើយខ្ញុំជឿរជាក់ថាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមប្រាកដជា សម្រេចថាទង្វើរបស់ខ្មែរក្រហមខាងលើដែលបានប្រព្រឹត្តលើជនជាតិឯង ក៏ត្រូវចាត់ចូលក្នុងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មអន្តជាតិផ្សេងៗទៀត ទោះបីជាតុលាការមិនទាន់បានចេញសេចក្តីសម្រេច ចុងក្រោយ ឬសាលក្រមដ៏ដោយ។